ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ
លេខ.១៩១ ប្រ.....អពដ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

L202506200395TD3418

ថ្ងៃសុក្រ ១០កើត ខែ ជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២៥

សេចក្តីណែនាំ
ស្តីពី
នីតិវិធីនៃការប្រកាសពន្ធលើប្រាក់ចំណូលរបស់អ្នកជាប់ពន្ធអនិវាសនជន ដែលប្រកបអាជីវកម្មដឹកជញ្ជូនទំនិញតាមផ្លូវទឹកជាអន្តរជាតិ ក្នុងប្រព័ន្ធគ្រប់គ្រងការប្រកាសពន្ធអាជីវកម្មតាមអនឡាញ (e-Filing)

អនុលោមតាមច្បាប់ស្តីពីសារពើពន្ធ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥២៣/០០៤ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣ និងប្រកាសលេខ ៤០៥ សហវ.ប្រក.អពដ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២៥ ស្តីពីកាតព្វកិច្ចសារពើពន្ធចំពោះសកម្មភាពអាជីវកម្មដឹកជញ្ជូនទំនិញតាមផ្លូវទឹកជាអន្តរជាតិ អគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានកិត្តិយសសូមជម្រាបជូន លោក លោកស្រីជាអភិបាល បណ្ណាធិការ ឬកម្មសិទ្ធិករ សហគ្រាស អ្នកជាប់ពន្ធ និងភ្នាក់ងារសេវាកម្មពន្ធដារ ឱ្យបានជ្រាបថា ស្របតាមទំនើបកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន អគ្គនាយកដ្ឋានពន្ធដារ បានអភិវឌ្ឍមុខងារ **"បញ្ជីពន្ធកាត់ទុក"** ដោយបន្ថែមប្រតិបត្តិការ **"ពន្ធកាត់ទុកលើអនិវាសនជន (ពន្ធលើប្រាក់ចំណូល) ៣%"** ក្នុងប្រព័ន្ធគ្រប់គ្រងការប្រកាសពន្ធអាជីវកម្មតាមអនឡាញ (e-Filing) រួចរាល់ ក្នុងគោលបំណងឱ្យសហគ្រាសដែលជាគ្រឹះស្ថានអចិន្ត្រៃយ៍របស់អ្នកជាប់ពន្ធអនិវាសនជន ដែលធ្វើសកម្មភាពដឹកជញ្ជូនទំនិញតាមផ្លូវទឹកជាអន្តរជាតិ និងមានកាតព្វកិច្ចកាត់ទុកពន្ធលើប្រាក់ចំណូលរបស់អ្នកជាប់ពន្ធអនិវាសនជននិងប្រកាសបង់ពន្ធ នៅក្នុងប្រព័ន្ធ e-Filing។

ក្នុងន័យនេះ អគ្គនាយកដ្ឋានពន្ធដារ សូមណែនាំអំពីនីតិវិធី និងការប្រើប្រាស់មុខងារបន្ថែមថ្មី ដូចខាងក្រោម៖

I. គោលការណ៍ និងនីតិវិធី

អនុលោមតាមកថាខណ្ឌ២ នៃប្រការ៨ នៃប្រកាសលេខ ៤០៥ សហវ.ប្រក.អពដ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២៥ សហគ្រាសដឹកជញ្ជូនទំនិញតាមផ្លូវទឹកជាអន្តរជាតិដែលជាអ្នកជាប់ពន្ធអនិវាសនជន និងប្រកបអាជីវកម្មតាមរយៈគ្រឹះស្ថានអចិន្ត្រៃយ៍ ត្រូវបង់ពន្ធលើប្រាក់ចំណូលតាមអត្រា ២០ (ម្ភៃ) ភាគរយ ចំពោះប្រាក់ចំណូលប្រភពកម្ពុជា។ មូលដ្ឋានគិតពន្ធលើប្រាក់ចំណូលចំពោះប្រាក់ចំណូលប្រភពកម្ពុជា ត្រូវកំណត់យកតាមកម្រិតនៃការបែងចែកប្រាក់ចំណូល (Attributable Income) ស្មើនឹង ១៥ (ដប់ប្រាំ) ភាគរយ នៃចំណូលដុលដែលទទួលបានពីការដឹកជញ្ជូនទំនិញតាមផ្លូវទឹកជាអន្តរជាតិចេញពីព្រះរាជាណាចក្រកម្ពុជាដល់គោលដៅចុងក្រោយ ដោយមិនគិតថាការទូទាត់ត្រូវបានធ្វើឡើងនៅក្នុងឬក្រៅព្រះរាជាណាចក្រកម្ពុជាឡើយ។

ចំពោះនីតិវិធីនៃការប្រកាសបង់ពន្ធ សហគ្រាសដែលជាគ្រឹះស្ថានអចិន្ត្រៃយ៍របស់អ្នកជាប់ពន្ធអនិវាសនជន ត្រូវមានកាតព្វកិច្ចកាត់ទុកពន្ធលើប្រាក់ចំណូលរបស់អ្នកជាប់ពន្ធអនិវាសនជននោះ តាមនីតិវិធីពន្ធកាត់ទុកលើអនិវាសនជន (ពន្ធលើប្រាក់ចំណូល) អត្រា៣% និងបង់ជូនរដ្ឋបាលសារពើពន្ធយ៉ាងយឺតបំផុតត្រឹមថ្ងៃទី២០ នៃខែបន្ទាប់ពីខែដែល

អគារកែងមហាវិថី សហព័ន្ធរុស្សី (១១០) និងម៉ៅសេទុង (២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (+855) 23 886 708 / ទូរសារ: (+855) 23 886 700, E-mail: gdt@tax.gov.kh, Website: www.tax.gov.kh

L202506200395TD3418

ការទូទាត់ថ្លៃដឹកជញ្ជូនបានកើតឡើង ដូចមានចែងក្នុងប្រការ៩ នៃប្រកាសលេខ ៤០៥ សហវ.ប្រក.អពដ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២៥។ ដើម្បីគណនាពន្ធកាត់ទុកលើអនិវាសនជន (ពន្ធលើប្រាក់ចំណូល) អត្រា៣% ត្រូវយក ចំណូលដុល × កម្រិតនៃការបែងចែកប្រាក់ចំណូល × អត្រាពន្ធលើប្រាក់ចំណូល ឬស្មើនឹង ចំណូលដុល × ១៥% × ២០%។

ចំពោះប្រាក់ចំណូលដុលរបស់អ្នកជាប់ពន្ធអនិវាសនជន សហគ្រាសដែលជាគ្រឹះស្ថានអចិន្ត្រៃយ៍របស់អ្នកជាប់ពន្ធ អនិវាសនជន មិនត្រូវកត់ត្រាចូលទៅក្នុងបញ្ជីទិនានុប្បវត្តិទិញ-លក់ នៅក្នុងប្រព័ន្ធ e-Filing របស់សហគ្រាសឡើយ។

II. **ការប្រើប្រាស់ប្រព័ន្ធ**

លោក លោកស្រី អាចចូលប្រកាស ពន្ធកាត់ទុកលើអនិវាសនជន (ពន្ធលើប្រាក់ចំណូល) ៣% នៃបញ្ជីពន្ធកាត់ទុក នៅក្នុងប្រព័ន្ធ e-Filing ដោយអនុវត្តតាមការណែនាំដូចខាងក្រោម៖

ជំហានទី១៖ ចូលប្រព័ន្ធគ្រប់គ្រងការប្រកាសពន្ធអាជីវកម្មតាមអនឡាញ (e-Filing) ដោយប្រើប្រាស់គណនី និងអនុវត្តនីតិវិធីដូចគ្នាទៅនឹងការប្រកាសពន្ធអាជីវកម្មប្រចាំខែ ដែលធ្លាប់បានអនុវត្តកន្លងមក។

ជំហានទី២៖ ជ្រើសរើស **"បញ្ចូលព័ត៌មានប្រកាសពន្ធ"** បន្ទាប់មកចូលមុខងារ **"បញ្ជីពន្ធកាត់ទុក"**។

ជំហានទី៣៖ បញ្ចូលប្រតិបត្តិការប្រកាសពន្ធកាត់ទុកលើអនិវាសនជន (ពន្ធលើប្រាក់ចំណូល) ៣% ដោយ ចុចប៊ូតុង **"បន្ថែមថ្មី"** បន្ទាប់មកបំពេញព័ត៌មានប្រតិបត្តិការ ហើយជ្រើសរើសប្រភេទប្រតិបត្តិការ **"ពន្ធកាត់ទុកលើអនិវាសនជន (ពន្ធលើប្រាក់ចំណូល) ៣%"** រួចចុច **"រក្សាទុក"**។

ជំហានទី៤៖ ចូលមុខងារ **"បញ្ជីប្រកាសពន្ធប្រចាំខែ"** ដើម្បីបន្តនីតិវិធីប្រកាសពន្ធដូចគ្នាទៅនឹងការប្រកាសពន្ធ អាជីវកម្មប្រចាំខែ ដែលធ្លាប់បានអនុវត្តកន្លងមក។

*ដើម្បីឈ្វេងយល់បន្ថែមអំពីនីតិវិធីខាងលើ អ្នកប្រើប្រាស់អាចអានសៀវភៅណែនាំស្តីពីការប្រើប្រាស់មុខងារ **បញ្ជីពន្ធកាត់ទុក** ដែលមាននៅលើគេហទំព័រ https://www.tax.gov.kh ឬទូរស័ព្ទមក GDT Call Center 1277 ឬចូលជជែកសួរក្នុង GDT Live Chat ដែលអាចទាញយកកម្មវិធីទូរស័ព្ទដៃចេញពី App Store សម្រាប់ iOS ឬ Play Store សម្រាប់ Android ឬតាមរយៈ Telegram Channel **ព័ត៌មានពន្ធដារកម្ពុជា**។*

អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សង្ឃឹមជឿជាក់យ៉ាងមុតមាំថា ការអនុវត្តវិធានការដូច បានជម្រាបជូនខាងលើ នឹងជួយសម្រួលដល់អ្នកជាប់ពន្ធទាំងអស់ក្នុងការបំពេញកាតព្វកិច្ចសារពើពន្ធជាក់ជាពុំខាន។

រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី
ប្រតិភូរាជរដ្ឋាភិបាល
ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ

គង់ វិបុល

Telegram Channel
ព័ត៌មានពន្ធដារកម្ពុជា